**Kingdom of Cambodia**
**National Religion King**

**Ministry of Health**
**No.**

# Notification
**on**
**Travel Conditions, Implementation of Health Rules and Quarantine in Cambodia for travelers entering Cambodia in line with the New Normal Context**

Through the proper leadership of the Royal Government, the introduction of measures and the establishment of effective and efficient mechanisms combined with the efforts of the Royal Government, civil servants and the armed forces at all levels, including the active participation of stakeholders from all walks of life, development partners, donors and citizens, has pushed the national **Covid-19 Vaccination Campaign** to build herd immunity in community across Cambodia to proceed smoothly and has significantly reduced the rate of infection and death. With the rate of vaccination approaching the planned target and seeing the improvement of the situation, the Royal Government has decided to reopen schools and plans to reopen full socio-economic activities gradually. "New Normal Context" by continuing to adhere to the highest vigilance

To ensure public health safety by strengthening the implementation of health measures more effectively, as well as to provide convenience to passengers who fully vaccinated, the Inter-Ministerial Commission for Combating Covid-19 decides on Travel Conditions, the Implementation of Health Measures and Quarantine in Cambodia for travelers entering Cambodia in accordance with the new normal context as follows:

- High-level international delegation and senior government officials returning from overseas missions (quarantine period decided by the Royal Government)
- Passengers who are civil servants returning from official missions abroad (3-day quarantine)
- Foreign diplomats and International Organization officers (3-day quarantine)
- Foreign tourists who are (investors, business people, experts with guarantee or invitation) (3 -day quarantine)
- General passenger who is Cambodian or foreigner (7- day quarantine)
- All type of passenger who have not vaccinated Covid-19 vaccine or not fully vaccinated (14-day period)

1. **International high-level delegations and senior government officials who return from overseas missions**

Travelers who are international high-level delegates and senior government officials returning from overseas missions must implement Health Measures and do the special quarantine according to the decision of the Royal Government based on each case.

## 2. Passengers who are civil servants returning from official missions abroad

### 2.1. Travel Conditions

Before arriving in Cambodia, travelers must prepare the following documents:

- Official mission letter issued by the ministry or institution
- Certificate confirming that there is no Covid-19 disease for 72 hours prior arriving Cambodia recognized by the health authority of the country on which the official on duty
- Must have a Covid-19 Vaccine card or certificate confirmation of complete vaccination type of vaccine, date of vaccination
- Hotel booking confirmation documents in case passengers want to be quarantined at the hotel which accepts online booking services.

Upon arrival at the Checking Point of Cambodia

- Passengers must present all relevant documents above
- Must cooperate to provide samples for PCR testing at the entry gate to Cambodia

### 2.2. Implementation of Health Measures

General Case:

After being checked the above required documents, passengers will be health checked and take a sample by health officials before being sent to a hotel or location designated by the Ministry of Health for quarantine.

- In case the passenger is not able to pay the quarantine fee at a hotel, the passenger has to go to the quarantine location and comply with the conditions set by the Ministry of Health and all expenses shall be covered by the national budget
- In case the passengers is able to pay the quarantine fee at the hotel itself, the coordinator at the entrance to Cambodia will arrange for passengers to be quarantined at hotel after being taken the sample.

Upon arrival at the quarantine location at a hotel or location designated by the Ministry of Health, passengers will be required to wait for the test results no later than 3 days:

- If the PCR test result is Covid-19 positive, passengers will be sent to the treatment center

designated by the Ministry of Health

- If the PCR test results confirmed Covid-19 negative, passengers will be ended the quarantine on the third day.

Note: In case the house of the above civil servant is favorable for doing quarantine in accordance with home quarantine measures, civil servants can request to the Second Sub-Committee at least 3 working days before arriving in Cambodia to do home quarantine. After reviewing the request, the Second Sub-Committee may reject or approve the permit by attaching the conditions and health measures for the passengers with high responsibility before the law of the Kingdom of Cambodia in force.

3. **Foreign diplomats and international organizations officials who hold type A diplomatic visas, type B official visa**

Visas for foreign diplomats and IOs officials holding diplomatic visas (Visa A) and official visas (Visa B) must apply as follows:

- Must apply 3- day quarantine measures
- Must have Covid-19 vaccination card or certificate confirming full vaccination, type of vaccine and date of vaccination
- Foreign diplomats and international organizations officials are required to have certification of Covid-19 negative within 72 hours prior arriving in Cambodia recognized by the health authorities of the country concerned.
- Foreign diplomats and IO officials can stay at separate embassy or residence as specified in the letter No.343 SKL dated 15 July 2021 of the Ministry of Health or hotel that can accept reservations such as Himawari Hotel, Sokha Phnom Penh Residence, Courtyard by Marriott, Raffles, Hotel Le Royal and Sofitel Phnom Penh Phokeethra, etc. for a full three-day quarantine and under the supervision of the Embassy, or International Organizations concerned and the health officer at all costs are the responsibility of the person concerned. For family members of diplomats or IOs officials who hold visas other than type A and B and have to be quarantined with persons who holds Type A and B visas also have to bear all the expenses by themselves during the quarantine.
- Those who have been quarantined are not allowed to meet guests or leave the quarantine location or room and must strictly adhere to the health measure issued by the Ministry of Health.
- Travel of the country's check point to the embassy residence or a separate house shall use only the means of transportation of the embassy or international organization. For travel to the hotel as mentioned above, it can be used only the means of transportation of the booked hotel.
- Diplomats and international organizations officials that receive Type A diplomatic visas and official type B visas must be tested upon the arrival in Cambodia and samples must be taken at special location at the passenger arrival terminal.
- In case of being found positive Covid-19 virus confirmed by laboratory of Pasteur Institute of Cambodia, patients must be referred to the Royal Phnom Penh Hospital or any other hospital requested by the Embassy and being agreed by the Ministry of Health to perform treatment. All medical treatment is the responsibility of the diplomat or the embassy and

the international organization itself.

## 4. Foreign travelers who are investors, businessmen, experts with guarantee or invitation

### 4.1. Mechanism of Guarantee or Invitation

Foreign travelers can be investors, business people or experts. To obtain a visa to enter Cambodia, they must have a guarantee or invitation from a local partner who is a legal entity, proper registration and payment of taxes in Cambodia. This guarantee and invitation mechanism is available through www.registrationservices.gov.kh attached with the following information:

- Company profile, Company name, registered certificate number, registration of Qualified Investment Project number or fiscal identification number, contact number, email address
- guarantor or invitee information, etc. name, date of birth, contact number, passport number or ID number
- Passenger information, such as name, date of birth, contact with guarantee, contact number, passport number, length of stay in Cambodia and purpose of travel to Cambodia.

Within 3 working days, the applicant will receive the following response:

- In case you do not agree, the applicant will receive a specific reason that can be corrected and re-apply
- In case of consent, the applicant will receive a certificate on guarantee letter or on invitation request.

Guarantee Certificate: is a letter stating that the applicant, who is the guarantor, is fully responsible for all costs related to quarantine and / or treatment in case a passenger has been infected with Covid-19 during the quarantine upon arrival in Cambodia. In this sense, the guarantor can use any hotel reservation service that accepts reservations for the quarantine and must have Certificate of purchase of Health Insurance for Covid-19 disease by purchasing Health Insurance from Forte Insurance Company through https://www.forteinsurance.com/covid-19-insurance/.

**Invitation Letter:** A letter stating that the passenger is solely responsible for all expenses. Passengers holding this type of certificate must deposit $ 2,000 upon arrival in Cambodia for payment of quarantine or treatment of Covid-19 expenses. Travelers can also use any hotel reservation service that accepts reservations for quarantine. In this case, the traveler is not required to deposit $ 2,000.

Both types of certificates are valid for 30 days and are in digital form that travelers can download and print themselves via the website.

## 4.2. Travel Conditions

Before traveling to Cambodia, foreign travelers must be prepared to meet the following essential requirements:

- Guarantee or Invitation Certificate is a required document for visa application, so it must be requested before applying for a visa
- Visa validity in accordance with the procedures of the Immigration Law issued by the Cambodian Embassy or Consulate of Cambodia
- Certificate of Negative Covid-19 within 72 hours prior to arrival in Cambodia, recognized by the health authority of the country concerned.
- Covid-19 Vaccination Certificate or certificate confirming the complete vaccination, vaccine type and date of Vaccination
- In case of using the invitation letter, the passenger must prepare $ 2,000 in cash to be deposited at the entrance check point of Cambodia for all costs associated with quarantine and / or treatment in case of passenger infected with Covid-19 during the quarantine upon arrival in Cambodia. In case the passenger already booked the quarantine service at any hotel, then, passengers do not need to deposit $ 2,000 and
- A certificate of purchase of health insurance (Health Insurance) for medical Covid-19 treatment: must buy the insurance from FORTE Insurance through https://www.forteinsurance.com/covid-19-insurance/.

Upon arrival at the check point of Cambodia, foreign travelers must present all of the above documents and deposit $ 2,000 in case the traveler uses the invitation letter and does not use the hotel reservation for quarantine service. Travelers holding a certificate of guarantee are not required to deposit $ 2,000, but must show booking document for quarantine at the hotel. The competent authority will scan the QR Code on the certificate of guarantee and the certificate of invitation of the passenger.

## 4.3. Implementation of Health Measures Upon Arrival in Cambodia

**General Case:** After fulfilling all the conditions in point 4.2 above, the traveler will be health checked and get sample tested by health officials upon arriving the quarantine location at the hotel or location designated by the Ministry of Health. Travelers must have to wait at least 3 days for test results:

- In case the PCR test result is Covid-19 positive, travelers will be sent to the treatment center designated by the Ministry of Health
- In case the PCR test result is Covid-19 negative, travelers will be ended the quarantine.

**Special case:** In case of necessity that the above travelers are not able to complete the full quarantine, the guarantor or the invitee must submit a request application to the Sub-

Committee on Entrance-Exit Management (called Sub-Committee II) in advance to request special principles for short-term quarantine. The guarantor or invitee must state the reasons and necessity of the short-term quarantine, including the detailed program of the visit to Cambodia. After reviewing the request, the second subcommittee may reject it with reasons or consent, including special health conditions and measures for passengers and guarantors to implement with high responsibility before the law of the Kingdom of Cambodia in force.

## 5. General Travelers who are Cambodians or Foreigners

General travelers are referred to Cambodians who hold a Cambodian passport or hold a foreign passport but have a K visa and foreign travelers who are company employees in Cambodia or their families.

### 5.1. For Cambodians

#### 5.1.1. Travel Conditions

**Before arriving in Cambodia**, travelers must prepare the following documents:

- Certificate of Negative Covid-19 within 72 hours prior to arrival in Cambodia, recognized by the health authorities of the country.
- Applicants must have a Covid-19 vaccination card or certificate confirming the complete vaccination, date of vaccination
- K type visa for Cambodian passengers holding foreign passports
- Hotel booking confirmation in case of passengers want to do the quarantine at a hotel that accepts online booking services.

**Upon arrival at the check point of Cambodia,** passengers must present all relevant documents above.

#### 5.1.2. Implementation of Health Measures

After being reviewed the above required documents, travelers will be health checked and taken samples by health officials before being sent to a hotel or location designated by the Ministry of Health for the quarantine.

- In case the passenger is not able to pay the quarantine fee at the hotel, the traveler has to sent go to the quarantine location and follow the conditions set by the Ministry of Health, and all expenses shall be covered by the national budget
- In case the passenger is able to pay the quarantine fee at the hotel itself, the liaison officer at the check point will arrange for the passengers to be quarantined at the hotel after being taken the sample.

Upon arrival at the quarantine location at the hotel or location designated by the Ministry of Health, travelers will have to wait for the result:

- In case of the result of the first test using Rapid Test (upon arrival in Cambodia) found positive Covid-19, the travelers will be sent for treatment center set by the Ministry of Health
- In case of the result of the first test using the Rapid Test is negative Covid-19, the traveler must continue to be quarantined for 7 days and traveler must be undergone a second PCR test on the 6th. If the result is Covid-19 positive, they will sent for treatment. In case the result is Covid-19 negative, they will be ended the quarantine.

## 5.2. For foreigners, foreign travelers

To obtain a visa to enter Cambodia, they must have a guarantee or invitation from the company in which they work, and the company must be a legitimate legal entity registered and properly taxed in Cambodia. This guarantee and invitation mechanism is available through www.registrationservices.gov.kh attached with the following information:

- Company name, business registration certificate number, QIP number or tax identification number, contact number, address, Email
- Information of guarantor or invitee, such as name, date of birth, contact number, passport number or ID card number
- Information of traveler such as, name, date of birth, contact with guarantor, contact number, passport number, length of stay in Cambodia and purpose of travel to Cambodia. Within 3 (3) working days, the applicant will receive the following response:

- In case you do not agree, the applicant will receive a specific reason that can be corrected and will re-apply
- In case of consent, the applicant will receive a certificate on guarantee or invitation.

**Guarantee Certificate:** is a letter stating that the applicant, who is the guarantor, is fully responsible for all costs related to quarantine and / or treatment in case a passenger has Covid-19 infection during the quarantine upon arrival in Cambodia. In this sense, the guarantor can use any hotel reservation service that accepts reservations for quarantine and must have a purchase confirmation letter of Health Insurance for Covid-19 by purchasing insurance from Forte Insurance through Website https://www.forteinsurance.com/covid-19-insurance/ .

**Invitation Letter:** is a letter stating that the passenger is solely responsible for all expenses. Travelers holding this type of certificate must deposit US $ 2,000 upon arrival in Cambodia for payment of quarantine and / or treatment of Covid-19. Travelers can also use any hotel reservation service that accepts reservations for quarantine. In this case traveler is not required to deposit $ 2,000.

Both types of certificates above are valid for 30 days and are in digital form that travelers can download and print themselves via the website.

### 5.2.1. Travel Conditions

**Before coming to Cambodia**, foreign travelers must well prepare to meet the following essential requirements below:

- Certificate of guarantee or Certificate of Invitation is a required document for the visa application, so it must be requested in advance.
- Visa which is valid in accordance with the procedures of the Immigration Law issued by the Cambodian Embassy or from the Consulate of Cambodia
- Work permit in case the passenger is an employee of the company, the guarantor or the invitee must apply for the work permit of the Ministry of Labor And vocational training through the website https://www.fismlvt.gov.kh/ before requesting a certificate of guarantee or certificate of invitation
- Negative Covid-19 certificate within 72 hours before arriving in Cambodia, recognized by the health authority of the concerned country
- Covid-19 vaccination certificate or certificate confirming the complete vaccination, vaccine type and date of vaccination
- In case of using the invitation letter, the traveler must prepare $ 2,000 in cash to be deposited at the entrance of Cambodian check point for the guarantee of all expenses related to quarantine and / or treatment in case the traveler infected Covid-19 during the quarantine upon arrival in Cambodia. If the traveler has already booked the quarantine service at a hotel, the traveler is not required to deposit $ 2,000 and
- Certificate of Purchase of Covid-19 Health Insurance: Must buy insurance from FORTE Insurance through https://www.forteinsurance.com/covid-19-insurance/ .

**Upon the arrival at Cambodian Check point,** foreign travelers must show all the documents mentioned above and deposit $ 2,000 in case the traveler uses the invitation letter and does not use the hotel reservation service for quarantine. Travelers holding a certificate of guarantee are not required to deposit $ 2,000, but must show booking documents for quarantine in hotel. The competent authority will scan the QR Code on the certificate of guarantee and the certificate of invitation of the travelers.

### 5.2.2. Implementation of Health Rules

After being reviewed on the above required documents, passengers will be health checked and will be taken samples by health officials before being sent to a hotel or location designated by the Ministry of Health for quarantine.

Upon the arrival at the quarantine location at a hotel or location designated by the Ministry of Health, travelers will have to wait for the result:

- In case the results of the first test using Rapid Test (upon arrival in Cambodia) is positive Covid-19, travelers will be sent for treatment center designated by the Ministry of Health
- In case of the result of the first test using the Rapid Test is negative Covid-19, the traveler must continue to do the quarantine for 7 days and will be taken the second sample test by PCR machine on the 6th day of quarantine. If the result is positive Covid-19, they must be sent for treatment. In case the result is negative Covid-19, they must be ended the quarantine.

6. **All types of travelers who have not been vaccinated Covid-19 vaccine or have not been fully vaccinated**

For the group of passengers mentioned above, in the event that they have not been injected Covid-19 vaccine have not been fully vaccinated, the travel conditions shall apply as mentioned above, but the duration of the quarantine is 14 days following health measure as followings:

Must collaborate with health officials to be taken samples for testing after arriving at quarantine at a hotel or location designated by the Ministry of Health and have to wait for the result:

- In case of the result of the first test using Rapid Test (upon arrival in Cambodia), is positive Covid-19, travelers will be sent to the treatment center designated by the Ministry of Health
- In case of the first Rapid Test result using the Rapid Test is negative Covid-19, travelers must continue to do the quarantine for 14 days and must be taken the second sample using PCR test on the 13th day of quarantine. If the result is positive Covid-19, they will be sent for treatment. In case the result is negative Covid-19, they will be ended the quarantine.

As mentioned above, please, all foreign travelers with a guarantee or invitation, foreign diplomats and officials of international organizations who hold a Type A and official B visa and civil servants or Cambodian travelers using Cambodian passports or foreign passports and foreigners in general, be informed and cooperate responsibly to jointly implement health measures of the Royal Government of Cambodia to fight with Covid-19 to be highly effective.

This announcement will be implemented from October 18, 2021 onwards.

Phnom Penh Date…………..
Minister of Health and
Chairman of the Inter-Ministerial Commission for Combating Covid-19

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
លេខ..........................

# សេចក្តីជូនដំណឹង
# ស្តីពី
# លក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានសុខាភិបាល និងការធ្វើចត្តាឡីស័កនៅកម្ពុជាសម្រាប់អ្នកដំណើរចូលមកកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី

តាមរយៈការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ការដាក់ចេញនូវវិធានការ និងការបង្កើតនូវយន្តការនានា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព គួបផ្សំនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ រួមទាំងការចូលរួមយ៉ាងសស្រាក់សស្រាំពីអ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋាន ទាំងបណ្តាដៃគូអភិវឌ្ឍន៍ សប្បុរសជន និងប្រជាពលរដ្ឋ បានជួយជំរុញឱ្យ **យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩** សំដៅបង្កើតភាពស៊ាំសហគមន៍នៅទូទាំងកម្ពុជា អាចដំណើរការទៅបានដោយរលូន និងធ្វើឱ្យអត្រានៃការឆ្លង និងស្លាប់បានធ្លាក់ចុះគួរឱ្យកត់សម្គាល់។ ដោយអត្រានៃការចាក់វ៉ាក់សាំងជិតសម្រេចបានតាមគោលដៅដែលបានគ្រោងទុក និងដោយមើលឃើញពីការវិវត្តកាន់តែប្រសើរឡើងនៃស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលបានសម្រេចបើកសាលារៀនឡើងវិញ ហើយគ្រោងនឹងបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចពេញលេញឡើងវិញជាបណ្តើរៗ តាម «**គន្លងប្រក្រតីភាពថ្មី**» ដោយបន្តប្រកាន់ខ្ជាប់នូវភាពប្រុងប្រយ័ត្នខ្ពស់ជានិច្ច។

ដើម្បីធានាសុវត្ថិភាពសុខភាពសាធារណៈ តាមរយៈការពង្រឹងការអនុវត្តវិធានសុខាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព ក៏ដូចជាដើម្បីផ្តល់ភាពងាយស្រួលដល់**អ្នកដំណើរដែលបានចាក់វ៉ាក់សាំងពេញលេញ** គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រេចកំណត់លក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានសុខាភិបាល និងការធ្វើចត្តាឡីស័កនៅកម្ពុជាសម្រាប់អ្នកដំណើរចូលមកកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី ដូចតទៅ៖

- គណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រលប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស (រយៈពេលចត្តាឡីស័កតាមការសម្រេចរបស់រាជរដ្ឋាភិបាល)
- អ្នកដំណើរជាមន្ត្រីរាជការដែលត្រលប់ពីបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេស (រយៈពេលចត្តាឡីស័ក **ចំនួន ៣ថ្ងៃ**)
- មន្ត្រីការទូតបរទេស និងមន្ត្រីអង្គការអន្តរជាតិ (រយៈពេលចត្តាឡីស័ក **ចំនួន ៣ថ្ងៃ**)
- អ្នកដំណើរបរទេសដែលជាវិនិយោគិន ធុរជន អ្នកជំនាញការ ដែលមានការធានា ឬការអញ្ជើញ (រយៈពេលចត្តាឡីស័ក **ចំនួន ៣ថ្ងៃ**)
- អ្នកដំណើរទូទៅដែលជាជនជាតិខ្មែរ ឬជនបរទេស (រយៈពេលចត្តាឡីស័ក **ចំនួន ៧ថ្ងៃ**)
- អ្នកដំណើរគ្រប់ប្រភេទដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងបានពេញលេញ (រយៈពេលចត្តាឡីស័ក **ចំនួន ១៤ថ្ងៃ**)។

**១- គណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រលប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស**

អ្នកដំណើរជាគណៈប្រតិភូជាន់ខ្ពស់អន្តរជាតិ និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលត្រលប់ពីបំពេញបេសកកម្មនៅក្រៅប្រទេសត្រូវអនុវត្តវិធានសុខាភិបាល និងការធ្វើចត្តាឡីស័កពិសេសតាមការសម្រេចរបស់រាជរដ្ឋាភិបាលដោយផ្អែកតាមករណីនីមួយៗ។

**២-អ្នកដំណើរជាមន្ត្រីរាជការដែលត្រលប់ពីបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេស**

**២.១-លក្ខខណ្ឌធ្វើដំណើរ**

**មុនពេលធ្វើដំណើរមកដល់កម្ពុជា** អ្នកដំណើរត្រូវត្រៀមឱ្យរួចរាល់នូវឯកសារ ដូចខាងក្រោម៖

- លិខិតបេសកកម្មផ្លូវការចេញដោយក្រសួង ឬស្ថាប័ន
- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសដែលមន្ត្រីបំពេញបេសកកម្ម
- ត្រូវមានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំង-និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ឯកសារបញ្ជាក់ការកក់សណ្ឋាគារ ក្នុងករណីអ្នកដំណើរចង់ធ្វើចត្តាឡីស័កនៅសណ្ឋាគារ ដែលទទួលសេវាកក់តាមអនឡាញ។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា**

- អ្នកដំណើរត្រូវបង្ហាញគ្រប់ឯកសារពាក់ព័ន្ធខាងលើ
- ត្រូវសហការផ្តល់សំណាកសម្រាប់ធ្វើតេស្តដោយម៉ាស៊ីន PCR នៅទីតាំងច្រកចូលប្រទេសកម្ពុជា។

**២.២-ការអនុវត្តវិធានសុខាភិបាល**

**ករណីទូទៅ៖** បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក។

- ក្នុងករណីអ្នកដំណើរគ្មានលទ្ធភាពបង់ថ្លៃសេវាចត្តាឡីស័កនៅសណ្ឋាគារ អ្នកដំណើរត្រូវទៅធ្វើចត្តាឡីស័កនៅតាមទីតាំង និងគោរពតាមលក្ខខណ្ឌ ដែលកំណត់ដោយក្រសួងសុខាភិបាល ហើយរាល់ចំណាយត្រូវជានាដោយថវិការដ្ឋ
- ក្នុងករណីអ្នកដំណើរមានលទ្ធភាពបង់ថ្លៃសេវាចត្តាឡីស័កនៅសណ្ឋាគារដោយខ្លួនឯង មន្ត្រីសម្របសម្រួលនៅច្រកចូលប្រទេសកម្ពុជា នឹងរៀបចំឱ្យអ្នកដំណើរបានទៅធ្វើចត្តាឡីស័កនៅសណ្ឋាគារបន្ទាប់ពីបានយកសំណាករួចរាល់។

ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផលតេស្តយ៉ាងយូរ **៣ថ្ងៃ៖**

- ក្នុងករណីលទ្ធផលតេស្តម៉ាស៊ីន PCR បញ្ជាក់ថា វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាលដែលកំណត់ដោយក្រសួងសុខាភិបាល
- ក្នុងករណីលទ្ធផលតេស្តម៉ាស៊ីន PCR បញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ចប់ការធ្វើចត្តាឡីស័កនៅថ្ងៃទី៣។

**កំណត់សម្គាល់៖** ក្នុងករណីគេហដ្ឋានរបស់មន្ត្រីរាជការខាងលើមានភាពអនុគ្រោះដល់ការធ្វើចត្តាឡីស័កស្របតាមវិធានការចត្តាឡីស័កនៅផ្ទះ អ្នកដំណើរជាមន្ត្រីរាជការអាចស្នើសុំមកអនុគណៈកម្មការទី២ យ៉ាងតិច៣ថ្ងៃនៃថ្ងៃធ្វើការ មុនពេលមកដល់កម្ពុជា ដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ក្រោយពីពិនិត្យលើការស្នើសុំ អនុគណៈកម្មការទី២ អាចបដិសេធ ឬឯកភាពអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌ និងវិធានសុខាភិបាលសម្រាប់អ្នកដំណើរអនុវត្តដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## ៣-មន្ត្រីការទូតបរទេស និងមន្ត្រីអង្គការអន្តរជាតិ ដែលកាន់ទិដ្ឋាការការទូតប្រភេទ A ទិដ្ឋាការផ្លូវការប្រភេទ B

ចំពោះមន្ត្រីការទូតបរទេស និងមន្ត្រីអង្គការអន្តរជាតិ ដែលកាន់ទិដ្ឋាការការទូត (Visa A) និងទិដ្ឋាការផ្លូវការ (Visa B) ត្រូវអនុវត្ត ដូចខាងក្រោម៖

- ត្រូវអនុវត្តវិធានការចត្តាឡីស័កចំនួន **៣ថ្ងៃ**
- ត្រូវមានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- មន្ត្រីការទូតបរទេស និងអង្គការអន្តរជាតិ តម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- មន្ត្រីការទូតបរទេស និងមន្ត្រីអង្គការអន្តរជាតិអាចស្នាក់នៅនិវេសនដ្ឋានរបស់ស្ថានទូត ឬគេហដ្ឋានដាច់ដោយឡែក ដូចមានបញ្ជាក់ក្នុងលិខិតលេខ៣៤៣ សខល ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ឬសណ្ឋាគារដែលអាចទទួលកក់បាន ដូចជាសណ្ឋាគារ Himawari, Sokha Phnom Penh Residence, Courtyard by Marriott, Raffles Hotel Le Royal និង Sofitel Phnom Penh Phokeethra ជាដើម ដើម្បីធ្វើចត្តាឡីស័ក ៣ថ្ងៃ ពេញលេញ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ស្ថានទូត អង្គការអន្តរជាតិសាមី និងមន្ត្រីសុខាភិបាល ដោយចំណាយទាំងអស់ជាបន្ទុករបស់សាមីខ្លួនផ្ទាល់។ ចំពោះសមាជិកគ្រួសាររបស់មន្ត្រីការទូត ឬមន្ត្រីអង្គការអន្តរជាតិដែលកាន់ទិដ្ឋាការប្រភេទផ្សេងពីប្រភេទ A និង B ហើយត្រូវធ្វើចត្តាឡីស័កជាមួយអ្នកកាន់ទិដ្ឋាការប្រភេទ A និង B ក៏ត្រូវទទួលរ៉ាប់រងរាល់ចំណាយផ្សេងៗ ដោយខ្លួនឯង ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក
- ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក អ្នកដែលត្រូវធ្វើចត្តាឡីស័កមិនត្រូវបានអនុញ្ញាតឱ្យជួបភ្ញៀវ ឬចាកចេញពីទីតាំង ឬបន្ទប់ចត្តាឡីស័កឡើយ ហើយត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានសុខាភិបាលនានា ដែលបានដាក់ចេញដោយក្រសួងសុខាភិបាល
- ការធ្វើដំណើរចេញពីច្រកទ្វារចេញ-ចូលប្រទេស ឆ្ពោះទៅកាន់និវេសនដ្ឋានរបស់ស្ថានទូត ឬគេហដ្ឋានដាច់ដោយឡែក ត្រូវប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនរបស់ស្ថានទូត ឬអង្គការអន្តរជាតិ។ ចំពោះការធ្វើដំណើរទៅសណ្ឋាគារដូចបានរៀបរាប់ខាងលើ ត្រូវប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនរបស់សណ្ឋាគារដែលបានកក់ហើយតែប៉ុណ្ណោះ
- មន្ត្រីការទូត និងអង្គការអន្តរជាតិដែលទទួលបានទិដ្ឋាការការទូតប្រភេទA និងទិដ្ឋាការផ្លូវការប្រភេទB ត្រូវធ្វើតេស្តទាំងអស់ ពេលមកដល់កម្ពុជា ហើយសំណាកត្រូវយកនៅទីតាំងពិសេសក្នុងស្ថានីយមកដល់របស់អ្នកដំណើរតែម្តង
- ក្នុងករណីមានការរកឃើញវីរុសកូវីដ-១៩ វិជ្ជមាន បញ្ជាក់ដោយមន្ទីរពិសោធន៍នៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អ្នកជំងឺត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ ឬមន្ទីរពេទ្យណាផ្សេងដែលស្ថានទូតសំណូមពរ ហើយដែលក្រសួងសុខាភិបាលឯកភាព ដើម្បីធ្វើការព្យាបាល។ រាល់ការការសម្រាកព្យាបាលជាបន្ទុករបស់មន្ត្រីការទូត ឬស្ថានទូត និងអង្គការអន្តរជាតិផ្ទាល់។

## ៤- អ្នកដំណើរបរទេសដែលជាវិនិយោគិន ធុរជន អ្នកជំនាញការ ដែលមានការធានា ឬការអញ្ជើញ

### ៤.១-យន្តការនៃការធានា ឬការអញ្ជើញ

អ្នកដំណើរបរទេសអាចជា **វិនិយោគិន ធុរជន ឬអ្នកជំនាញការ។** ដើម្បីទទួលបានទិដ្ឋាការចូលមកកម្ពុជាអ្នកទាំងនោះត្រូវមានការធានា ឬការអញ្ជើញពីដៃគូក្នុងស្រុក ដែលជានីតិបុគ្គលស្របច្បាប់ មានការចុះបញ្ជី និងបង់ពន្ធត្រឹមត្រូវនៅកម្ពុជា។ យន្តការនៃការធានា និងការអញ្ជើញនេះ ត្រូវធ្វើតាមរយៈគេហទំព័រ www.registrationservices.gov.kh ដោយភ្ជាប់នូវព័ត៌មាន ដូចខាងក្រោម៖

- ព័ត៌មានរបស់ក្រុមហ៊ុន ជាអាទិ៍ ឈ្មោះក្រុមហ៊ុន លេខវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬលេខអត្តសញ្ញាណកម្មសារពើពន្ធ លេខទំនាក់ទំនង អាសយដ្ឋាន អ៊ីម៉ែល
- ព័ត៌មានរបស់អ្នកធានា ឬអ្នកអញ្ជើញ ជាអាទិ៍ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខទំនាក់ទំនង លេខលិខិតឆ្លងដែន ឬលេខអត្តសញ្ញាណប័ណ្ណ
- ព័ត៌មានរបស់អ្នកដំណើរ ជាអាទិ៍ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ទំនាក់ទំនងជាមួយអ្នកធានា លេខទំនាក់ទំនង លេខលិខិតឆ្លងដែន រយៈពេលស្នាក់នៅកម្ពុជា និង វត្ថុបំណងនៃការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា។

ក្នុងរយៈពេលយ៉ាងយូរ**៣(បី)ថ្ងៃនៃថ្ងៃធ្វើការ** អ្នកស្នើសុំនឹងទទួលបាននូវការឆ្លើយតបដូចខាងក្រោម៖

- ក្នុងករណីមិនឯកភាព អ្នកស្នើសុំនឹងទទួលបាននូវមូលហេតុជាក់លាក់មួយ ដែលអាចធ្វើការកែតម្រូវនឹងធ្វើការស្នើសុំម្តងទៀត
- ក្នុងករណីឯកភាព អ្នកស្នើសុំនឹងទទួលបានលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញតាមការស្នើសុំ។

**លិខិតបញ្ជាក់លើការធានា៖** ជាលិខិតដែលបញ្ជាក់ថា អ្នកស្នើសុំដែលជាអ្នកធានា គឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក និង/ឬ ការព្យាបាល ក្នុងករណីដែលអ្នកដំណើរមានការឆ្លងជំងឺកូវីដ-១៩ ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។ ក្នុងន័យនេះ អ្នកធានាអាចប្រើប្រាស់សេវាកក់សណ្ឋាគារណាមួយដែលទទួលកក់សម្រាប់ការធ្វើចត្តាឡីស័ក និងត្រូវមានលិខិតបញ្ជាក់ការទិញសេវាធានារ៉ាប់រងសុខភាព (Health Insurance) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ដោយត្រូវទិញធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងហ្វតេ តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/។

**លិខិតបញ្ជាក់លើការអញ្ជើញ៖** ជាលិខិតដែលបញ្ជាក់ថា អ្នកដំណើរគឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើការចំណាយទាំងអស់ដោយខ្លួនឯង។ អ្នកដំណើរដែលកាន់លិខិតបញ្ជាក់ប្រភេទនេះ ត្រូវតែតម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិក ពេលមកដល់ប្រទេសកម្ពុជា សម្រាប់ការទូទាត់លើការធ្វើចត្តាឡីស័ក និង/ឬការព្យាបាលជំងឺកូវីដ-១៩។ អ្នកដំណើរក៏អាចប្រើប្រាស់សេវាកក់សណ្ឋាគារណាមួយដែលទទួលកក់សម្រាប់ការធ្វើចត្តាឡីស័កបានផងដែរ ក្នុងករណីនេះអ្នកដំណើរ មិនចាំបាច់តម្កល់ប្រាក់ចំនួន២ ០០០ ដុល្លារអាមេរិក នោះទេ។

លិខិតបញ្ជាក់ទាំងពីរប្រភេទខាងលើ មានសុពលភាព ៣០ ថ្ងៃ និងមានទម្រង់ឌីជីថល ដែលអ្នកដំណើរអាចទាញយក និងបោះពុម្ពបានដោយខ្លួនឯង តាមគេហទំព័រខាងលើ។

### ៤.២-លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកកម្ពុជា** អ្នកដំណើរបរទេសត្រូវត្រៀមរៀបចំឱ្យរួចរាល់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវសំខាន់ៗ ដូចខាងក្រោម៖

- លិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញ គឺជាឯកសារតម្រូវ សម្រាប់ការស្នើសុំទិដ្ឋាការ ដូច្នេះត្រូវស្នើសុំឱ្យបានមុនការស្នើសុំទិដ្ឋាការ
- ទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលត្រូវបានផ្តល់ឱ្យពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា

- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- បណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ក្នុងករណីប្រើប្រាស់លិខិតបញ្ជាក់លើការអញ្ជើញ អ្នកដំណើរត្រូវត្រៀមសាច់ប្រាក់ចំនួន ២ ០០០ ដុល្លារអាមេរិក ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក និង/ឬ ការព្យាបាល ក្នុងករណីដែលអ្នកដំណើរមានការឆ្លងជំងឺកូវីដ-១៩ ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។ ក្នុងករណីអ្នកដំណើរបានកក់សេវាចត្តាឡីស័កនៅសណ្ឋាគារណាមួយរួចហើយ នោះអ្នកដំណើរមិនចាំបាច់តម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិកនោះទេ និង
- លិខិតបញ្ជាក់ការទិញសេវាធានារ៉ាប់រងសុខភាព (Health Insurance) សម្រាប់ព្យាបាលជំងឺកូវីដ-១៩៖ ត្រូវទិញធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ (FORTE Insurance) តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/ ។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរបរទេស ត្រូវបង្ហាញគ្រប់ឯកសារ ដែលរៀបរាប់ខាងលើ និងតម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិក ក្នុងករណីអ្នកដំណើរប្រើប្រាស់លិខិតបញ្ជាក់លើការអញ្ជើញ និងមិនបានប្រើប្រាស់សេវាកក់សណ្ឋាគារសម្រាប់ធ្វើចត្តាឡីស័ក។ អ្នកដំណើរដែលកាន់លិខិតបញ្ជាក់លើការធានា មិនតម្រូវឱ្យតម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិកនោះទេ ប៉ុន្តែត្រូវបង្ហាញឯកសារបញ្ជាក់ថាបានកក់សណ្ឋាគារសម្រាប់ធ្វើចត្តាឡីស័ក។ អាជ្ញាធរមានសមត្ថកិច្ច នឹងស្កេន QR Code លើលិខិតបញ្ជាក់លើការធានា និងលិខិតបញ្ជាក់លើការអញ្ជើញរបស់អ្នកដំណើរ។

### ៤.៣-ការអនុវត្តវិធានសុខាភិបាល នៅពេលមកដល់កម្ពុជា

**ករណីទូទៅ៖** បន្ទាប់ពីបានបំពេញគ្រប់លក្ខខណ្ឌក្នុងចំណុច ៤.២ ខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផលតេស្តយ៉ាងយូរ **៣ថ្ងៃ**៖

- ក្នុងករណីលទ្ធផលតេស្តម៉ាស៊ីន PCR បញ្ជាក់ថា វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាលដែលកំណត់ដោយក្រសួងសុខាភិបាល
- ក្នុងករណីលទ្ធផលតេស្តម៉ាស៊ីន PCR បញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក។

**ករណីពិសេស៖** ក្នុងករណីចាំបាច់ដែលអ្នកដំណើរខាងលើមិនអាចធ្វើចត្តាឡីស័កពេញលេញ អ្នកធានា ឬអ្នកអញ្ជើញ ត្រូវដាក់លិខិតស្នើសុំទៅអនុគណៈកម្មការគ្រប់គ្រងទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក (ហៅកាត់ថា អនុគណៈកម្មការទី២) ជាមុន ដើម្បីស្នើសុំគោលការណ៍ពិសេសសម្រាប់ការធ្វើចត្តាឡីស័ករយៈពេលខ្លី។ អ្នកធានា ឬអ្នកអញ្ជើញ ត្រូវបង្ហាញពីហេតុផល និងភាពចាំបាច់នៃការធ្វើចត្តាឡីស័ករយៈពេលខ្លី រួមទាំងកម្មវិធីលម្អិតនៃការធ្វើដំណើរមកកម្ពុជា។ ក្រោយពីពិនិត្យលើការស្នើសុំ អនុគណៈកម្មការទី២ អាចបដិសេធដោយភ្ជាប់នូវហេតុផល ឬឯកភាពអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌ និងវិធានសុខាភិបាលពិសេស សម្រាប់អ្នកដំណើរ និងអ្នកធានាអនុវត្ត ដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## ៥-អ្នកដំណើរទូទៅជាជនជាតិខ្មែរ ឬជនបរទេស

អ្នកដំណើរទូទៅសំដៅដល់ជនជាតិខ្មែរដែលកាន់លិខិតឆ្លងដែនខ្មែរ ឬកាន់លិខិតឆ្លងដែនបរទេស ប៉ុន្តែមានទិដ្ឋាការប្រភេទ K និងអ្នកដំណើរបរទេសដែលជា **បុគ្គលិកក្រុមហ៊ុននៅកម្ពុជា ឬក្រុមគ្រួសាររបស់គេ**។

### ៥.១-សម្រាប់ជនជាតិខ្មែរ

### ៥.១.១-លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកដល់កម្ពុជា** អ្នកដំណើរត្រូវត្រៀមឱ្យរួចរាល់នូវឯកសារ ដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- ត្រូវមានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំង-និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ទិដ្ឋាការប្រភេទ K ក្នុងករណីអ្នកដំណើរជាជនជាតិខ្មែរកាន់លិខិតឆ្លងដែនបរទេស
- ឯកសារបញ្ជាក់ការកក់សណ្ឋាគារ ក្នុងករណីអ្នកដំណើរចង់ធ្វើចត្តាឡីស័កនៅសណ្ឋាគារ ដែលទទួលសេវាកក់តាមអនឡាញ។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរត្រូវបង្ហាញគ្រប់ឯកសារពាក់ព័ន្ធខាងលើ។

### ៥.១.២-ការអនុវត្តវិធានសុខាភិបាល

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក។

- ក្នុងករណីអ្នកដំណើរគ្មានលទ្ធភាពបង់ថ្លៃសេវាចត្តាឡីស័កនៅសណ្ឋាគារ អ្នកដំណើរត្រូវទៅធ្វើចត្តាឡីស័កនៅតាមទីតាំង និងគោរពតាមលក្ខខណ្ឌ ដែលកំណត់ដោយក្រសួងសុខាភិបាល ហើយរាល់ចំណាយត្រូវធានាដោយថវិការដ្ឋ
- ក្នុងករណីអ្នកដំណើរមានលទ្ធភាពបង់ថ្លៃសេវាចត្តាឡីស័កនៅសណ្ឋាគារដោយខ្លួនឯង មន្ត្រីសម្របសម្រួលនៅតាមច្រកទ្វារចេញ-ចូលប្រទេស នឹងរៀបចំឱ្យអ្នកដំណើរបានទៅធ្វើចត្តាឡីស័កនៅសណ្ឋាគារ បន្ទាប់ពីបានយកសំណាករួចរាល់។

ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផល៖

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាលដែលកំណត់ដោយក្រសួងសុខាភិបាល
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន **៧ថ្ងៃ** ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី៦។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក។

### ៥.២-សម្រាប់ជនបរទេស

អ្នកដំណើរជាជនបរទេស ដើម្បីទទួលបានទិដ្ឋាការចូលមកកម្ពុជា អ្នកទាំងនោះត្រូវមានការធានា ឬការអញ្ជើញពីក្រុមហ៊ុនដែលខ្លួនត្រូវបំពេញការងារ ហើយក្រុមហ៊ុននោះត្រូវជានីតិបុគ្គលស្របច្បាប់ មានការចុះបញ្ជី និងបង់ពន្ធត្រឹមត្រូវនៅកម្ពុជា។ យន្តការនៃការធានា និងការអញ្ជើញនេះ ត្រូវធ្វើតាមរយៈគេហទំព័រ www.registrationservices.gov.kh ដោយភ្ជាប់នូវព័ត៌មាន ដូចខាងក្រោម៖

- ព័ត៌មានរបស់ក្រុមហ៊ុន ជាអាទិ៍ ឈ្មោះក្រុមហ៊ុន លេខវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬលេខអត្តសញ្ញាណកម្មសារពើពន្ធ លេខទំនាក់ទំនង អាសយដ្ឋាន អ៊ីម៉ែល

- ព័ត៌មានរបស់អ្នកធានា ឬអ្នកអញ្ជើញ ជាអាទិ៍ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខទំនាក់ទំនង លេខលិខិតឆ្លងដែន ឬលេខអត្តសញ្ញាណប័ណ្ណ
- ព័ត៌មានរបស់អ្នកដំណើរ ជាអាទិ៍ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ទំនាក់ទំនងជាមួយអ្នកធានា លេខទំនាក់ទំនង លេខលិខិតឆ្លងដែន រយៈពេលស្នាក់នៅកម្ពុជា និង វត្ថុបំណងនៃការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា។

ក្នុងរយៈពេលយ៉ាងយូរ**៣(បី)ថ្ងៃនៃថ្ងៃធ្វើការ** អ្នកស្នើសុំនឹងទទួលបាននូវការឆ្លើយតបដូចខាងក្រោម៖
- ក្នុងករណីមិនឯកភាព អ្នកស្នើសុំនឹងទទួលបាននូវមូលហេតុជាក់លាក់មួយ ដែលអាចធ្វើការកែតម្រូវនឹងធ្វើការស្នើសុំម្តងទៀត
- ក្នុងករណីឯកភាព អ្នកស្នើសុំនឹងទទួលបានលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញតាមការស្នើសុំ។

**លិខិតបញ្ជាក់លើការធានា៖** ជាលិខិតដែលបញ្ជាក់ថា អ្នកស្នើសុំដែលជាអ្នកធានា គឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក និង/ឬ ការព្យាបាល ក្នុងករណីដែលអ្នកដំណើរមានការឆ្លងជំងឺកូវីដ-១៩ ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។ ក្នុងន័យនេះ អ្នកធានាអាចប្រើប្រាស់សេវាកក់សណ្ឋាគារណាមួយដែលទទួលកក់សម្រាប់ការធ្វើចត្តាឡីស័ក និងត្រូវមានលិខិតបញ្ជាក់ការទិញសេវាធានារ៉ាប់រងសុខភាព (Health Insurance) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ដោយត្រូវទិញធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/។

**លិខិតបញ្ជាក់លើការអញ្ជើញ៖** ជាលិខិតដែលបញ្ជាក់ថា អ្នកដំណើរគឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើការចំណាយទាំងអស់ដោយខ្លួនឯង។ អ្នកដំណើរដែលកាន់លិខិតបញ្ជាក់ប្រភេទនេះ ត្រូវតម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិក ពេលមកដល់ប្រទេសកម្ពុជា សម្រាប់ការទូទាត់លើការធ្វើចត្តាឡីស័ក និង/ឬការព្យាបាលជំងឺកូវីដ-១៩។ អ្នកដំណើរក៏អាចប្រើប្រាស់សេវាកក់សណ្ឋាគារណាមួយដែលទទួលកក់សម្រាប់ការធ្វើចត្តាឡីស័កបានផងដែរ ក្នុងករណីនេះអ្នកដំណើរ មិនចាំបាច់តម្កល់ប្រាក់ចំនួន២ ០០០ ដុល្លារអាមេរិក នោះទេ។

លិខិតបញ្ជាក់ទាំងពីរប្រភេទខាងលើ មានសុពលភាព ៣០ ថ្ងៃ និងមានទម្រង់ឌីជីថល ដែលអ្នកដំណើរអាចទាញយក និងបោះពុម្ពបានដោយខ្លួនឯង តាមគេហទំព័រខាងលើ។

### ៥.២.១-លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកកម្ពុជា** អ្នកដំណើរបរទេសត្រូវត្រៀមរៀបចំឱ្យរួចរាល់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវសំខាន់ៗ ដូចខាងក្រោម៖
- លិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញ គឺជាឯកសារតម្រូវ សម្រាប់ការស្នើសុំទិដ្ឋាការ ដូច្នេះត្រូវស្នើសុំឱ្យបានមុនការស្នើសុំទិដ្ឋាការ
- ទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលត្រូវបានផ្តល់ឱ្យពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា
- បណ្ណការងារ ក្នុងករណីអ្នកដំណើរជាបុគ្គលិកក្រុមហ៊ុន អ្នកធានាឬអ្នកអញ្ជើញត្រូវធ្វើការស្នើសុំបណ្ណការងាររបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគេហទំព័រ https://www.fwcms.mlvt.gov.kh/ មុនការស្នើសុំលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញ
- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- បណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ក្នុងករណីប្រើប្រាស់លិខិតបញ្ជាក់លើការអញ្ជើញ អ្នកដំណើរត្រូវត្រៀមសាច់ប្រាក់ចំនួន ២ ០០០ ដុល្លារអាមេរិក ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក និង/ឬ ការព្យាបាល ក្នុងករណីដែលអ្នកដំណើរមានការឆ្លងជំងឺកូវីដ-១៩ ក្នុងអំឡុងពេលធ្វើ

ចត្តាឡីស័កនៅពេលមកដល់កម្ពុជា។ ក្នុងករណីអ្នកដំណើរបានកក់សេវាចត្តាឡីស័កនៅសណ្ឋាគារណាមួយរួចហើយ នោះអ្នកដំណើរមិនចាំបាច់តម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិកនោះទេ និង

- លិខិតបញ្ជាក់ការទិញសេវាធានារ៉ាប់រងសុខភាព (Health Insurance) សម្រាប់ព្យាបាលជំងឺកូវីដ-១៩៖ ត្រូវទិញធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ (FORTE Insurance) តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/ ។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរបរទេស ត្រូវបង្ហាញគ្រប់ឯកសារ ដែលរៀបរាប់ខាងលើ និងតម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិក ក្នុងករណីអ្នកដំណើរប្រើប្រាស់លិខិតបញ្ជាក់លើការអញ្ជើញ និងមិនបានប្រើប្រាស់សេវាកក់សណ្ឋាគារសម្រាប់ធ្វើចត្តាឡីស័ក។ អ្នកដំណើរដែលកាន់លិខិតបញ្ជាក់លើការធានា មិនតម្រូវឱ្យតម្កល់ប្រាក់ ២ ០០០ ដុល្លារអាមេរិកនោះទេ ប៉ុន្តែត្រូវបង្ហាញឯកសារបញ្ជាក់ថាបានកក់សណ្ឋាគារសម្រាប់ធ្វើចត្តាឡីស័ក។ អាជ្ញាធរមានសមត្ថកិច្ច នឹងស្កេន QR Code លើលិខិតបញ្ជាក់លើការធានា និងលិខិតបញ្ជាក់លើការអញ្ជើញរបស់អ្នកដំណើរ។

### ៥.២.២-ការអនុវត្តវិធានសុខាភិបាល

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក។

ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផល៖

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាលដែលកំណត់ដោយក្រសួងសុខាភិបាល
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន **៧ថ្ងៃ** ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី៦នៃការធ្វើចត្តាឡីស័ក។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក។

## ៦-អ្នកដំណើរគ្រប់ប្រភេទ ដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងបានពេញលេញ

ចំពោះក្រុមអ្នកដំណើរដែលបានរៀបរាប់ខាងលើ ករណីមិនទាន់បានចាក់វ៉ាក់កូវីដ-១៩ ឬចាក់វ៉ាក់សាំងមិនទាន់បានពេញលេញ ការអនុវត្តលក្ខខណ្ឌធ្វើដំណើរ ត្រូវអនុវត្តដូចបានរៀបរាប់ខាងលើ ប៉ុន្តែរយៈនៃការធ្វើចត្តាឡីស័កគឺចំនួន **១៤ថ្ងៃ** ដោយត្រូវអនុវត្តវិធានសុខាភិបាលដូចខាងក្រោម៖

ត្រូវសហការឱ្យមន្ត្រីសុខាភិបាលធ្វើការយកសំណាក ហើយក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផល៖

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាលដែលកំណត់ដោយក្រសួងសុខាភិបាល
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន **១៤ថ្ងៃ** ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី១៣នៃការធ្វើចត្តាឡីស័ក។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមអ្នកដំណើរបរទេស ដែលមានការជានា ឬការអញ្ជើញ មន្ត្រីការទូតបរទេស និងមន្ត្រីអង្គការអន្តរជាតិ ដែលកាន់ទិដ្ឋាការការទូតប្រភេទ A និងទិដ្ឋាការផ្លូវការប្រភេទ B និងអ្នកដំណើរជាមន្ត្រីរាជការ ឬអ្នកដំណើរជាជនជាតិខ្មែរ ដែលប្រើប្រាស់លិខិតឆ្លងដែនកម្ពុជា ឬលិខិតឆ្លងដែនបរទេស និងជនបរទេសទូទៅ មេត្តាជ្រាប និងចូលរួមសហការប្រកបដោយការទទួលខុសត្រូវ ដើម្បីរួមគ្នាអនុវត្តវិធានការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់។

**សេចក្តីជូនដំណឹងនេះ នឹងអនុវត្តចាប់ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ តទៅ។**

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**

**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**